ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

មន្ទីរពេទ្យ កាល់ម៉ែត

HOPITAL Calmette

គណៈកម្មាធិការលទ្ធកម្ម

លេខ ០៤១៣ កម/២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ សម្ភារៈការិយាល័យ សម្រាប់មន្ទីរពេទ្យកាល់ម៉ែត ឆ្នាំ ២០១៩

មន្ទីរពេទ្យកាល់ម៉ែតសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា មន្ទីរពេទ្យកាល់ម៉ែតនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ **សម្ភារៈការិយាល័យ** ជូនមន្ទីរពេទ្យកាល់ម៉ែត ឆ្នាំ ២០១៩ ដោយប្រើប្រាស់**ថវិកាស្វយ័តមន្ទីរពេទ្យ កាល់ម៉ែត** ។

មន្ទីរពេទ្យកាល់ម៉ែតបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់ក្នុងតម្លៃ **២៩៤ 000** (ពីររយកៅសិបបួនពាន់) **រៀល** នៅមន្ទីរពេទ្យកាល់ម៉ែត លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ ទូរស័ព្ទលេខ ០៣៣ ៦២៣ ៥៩៣ ។

កាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃនៅម៉ោង **០៩:០០ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០១៩** ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអាសយដ្ឋានខាងលើ **វេលាម៉ោង ០៩:០០ នាទី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០១៩** ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មមន្ទីរពេទ្យកាល់ម៉ែត ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩

**អគ្គនាយកមន្ទីរពេទ្យ និងជា**

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**សាស្ត្រាចារ្យ ឈាង រ៉ា**

<u>ចម្លងជូន :</u>

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ